ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៤៦ ប្រក

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលគ្រប់ខេត្ត ក្រុងក្នុងការចាត់ចែង ដំណើរការកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**ប្រការ ១.-**

ធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងឱ្យទទួលខុសត្រូវអំពីដំណើរការចាត់ចែងការប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីស្ថិតក្នុងខេត្ត ក្រុងរបស់ខ្លួន។

**ប្រការ ២.-**

អភិបាលខេត្ត ក្រុងមានសិទ្ធិអំណាចក្នុងការចាត់តាំងមន្ត្រីឱ្យធ្វើជាអធិបតីនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។ មន្ត្រីទាំងនោះ រួមមានអភិបាល ឬ អភិបាលរងស្រុក ខណ្ឌ ប្រធាន ឬ អនុប្រធានមន្ទីរសាលាស្រុក ខណ្ឌ ឬ អនុប្រធាននៃអង្គភាពទាំងប្រាំចំណុះឱ្យសាលាខេត្ត ក្រុងឡើងទៅ។

**ប្រការ ៣.-**

អភិបាលខេត្ត ក្រុង និង មន្ត្រីដែលធ្វើជាអធិបតី នៃអង្គប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវអនុវត្តតួនាទី និង ភារកិច្ចឱ្យបានសមស្របទៅតាមសេចក្តីណែនាំស្តីពីការរៀបចំកិច្ចប្រជុំលើកដំបូង ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ព្រមទាំងណែនាំអំពីការចាប់ផ្តើមបំពេញការងារបន្ទាប់ពីកិច្ចប្រជុំលើកដំបូង។

**ប្រការ ៤.-**

ប្រកាសលេខ ១២៦ ប្រក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចក្នុងការចាត់ចែងដំណើរការកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដល់អភិបាលខេត្ត ក្រុង ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០៧*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ចម្លងជូន:**

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរបស់រាជរដ្ឋាភិបាល*
- *គ្រប់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

  *"ដើម្បីជូនជ្រាប"*
- *ដូចប្រការ ៥*

  *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*